## ព្រះរាជក្រម

នស/រកម/០៦១៨/ ០០៩

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធ កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ទទួល ចូល
លេខ.......
ថ្ងៃទី....... ឆ្នាំ....... ម៉ោង.......
បញ្ជូនទៅ.......

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • MINISTERE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើ

ដោយព្រះរាជក្រមលេខ

នស/រកម/០៧០១/០៩

ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.–**

មាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០នៃច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០១ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ៖

**មាត្រា៣.–ថ្មី**

ធនធានរ៉ែគឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័នដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ត្បូងថ្ម ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន ។

ប្រតិបត្តិការធនធានរ៉ែគឺជាការធ្វើសកម្មភាព បុរេសនា ស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

បុរេសនាគឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាបណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ ។

ការស្វែងរុករកគឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្និស្សន៍រ៉ែ ដើម្បីកំណត់ សក្តានុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្ររូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការជីកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ។

អាជីវកម្មធនធានរ៉ែគឺជាប្រតិបត្តិការជីកយកធនធានរ៉ែ ដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម ។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហធាតុមានតម្លៃ ត្បូងថ្មមានតម្លៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន ។

ផលិតផលរ៉ែសំដៅដល់ផលិតផលរ៉ែដែលបានមកពីការធ្វើប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណធនធានរ៉ែពីក្រសួងទទួលបន្ទុកវិស័យរ៉ែ ។

**មាត្រា២៣.–ថ្មី**

រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវចាត់តាំងមន្ត្រីអធិការកិច្ចធនធានរ៉ែដើម្បីពិនិត្យការអនុវត្តច្បាប់នេះ ។

មន្ត្រីអធិការកិច្ចធនធានរ៉ែមានសិទ្ធិ ៖

- ធ្វើអធិការកិច្ចក្នុងតំបន់អាជ្ញាបណ្ណដើម្បីកំណត់វាយតម្លៃអំពីស្ថានភាពប្រតិបត្តិការធនធានរ៉ែ និងពិនិត្យអនុលោមភាពតាមច្បាប់ គោលការណ៍បច្ចេកទេស និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងការការពារបរិស្ថាននិងសង្គម
- តម្រូវឱ្យផ្អាកជាបណ្តោះអាសន្ន ឬកែប្រែប្រតិបត្តិការធនធានរ៉ែក្នុងករណីដែលប្រតិបត្តិការធនធានរ៉ែនោះអាចបង្កគ្រោះថ្នាក់ ឬហានិភ័យធ្ងន់ធ្ងរដល់សុវត្ថិភាពពលកម្ម និង/ឬបរិស្ថាន
- ផ្អាកឬឃាត់ទុកមធ្យោបាយផលិតកម្មដែលធ្វើប្រតិបត្តិការធនធានរ៉ែល្មើសច្បាប់ ឬមធ្យោបាយដឹកជញ្ជូនធនធានរ៉ែដោយខុសច្បាប់ ឬមិនត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស